ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ៖ D87/2/3

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ១០/១)

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម និយ ថុល |
| | ចៅក្រម Chang-Ho CHUNG |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៤ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 09 / 2014
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**សម្ងាត់**

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើរបស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងសុំចូលរួមកិច្ចស៊ើបសួរ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារម្ចាស់បណ្តឹងឧទ្ធរណ៍:**

អាងឧត្តម
Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីណា
វ៉ែន ពៅ
Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN

Emmanuel JACOMY

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") នៅតែទទួល[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹង "ការបដិសេធតាមការសន្មត" របស់សហចៅក្រមស៊ើបអង្កេត ចំពោះ "សំណើរបស់ [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងសុំចូលរួមក្នុងកិច្ចស៊ើបសួរ" ("សំណើ")[2] ដែលបានដាក់ដោយលោក អាង ឧត្តម និងលោក Michael G. KARNAVAS ("សហមេធាវី") ក្នុងនាម [redacted] នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("បណ្តឹងឧទ្ធរណ៍") ជាផ្នែកមួយនៃ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធដោយសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ ក.ស.ច.ស" របស់ពួកគេ ("បណ្តឹងឧទ្ធរណ៍")[3]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាស្តីទី បានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ពាក់ព័ន្ធនឹង [redacted] ដោយបើកកិច្ចស៊ើបសួរចំពោះបទឧក្រិដ្ឋនានា*ក្នុងចំណោមនោះ* ដែលចោទប្រកាន់ថា [redacted] ជាអ្នកទទួលខុសត្រូវ[4]។

២. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ("ស.ច.ស.អ.ប") បានចេញ *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* ដោយជូនដំណឹងទៅ [redacted] ថា គាត់*ជាប់ឈ្មោះជាជនសង្ស័យម្នាក់* នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ *ទាក់ទិននឹងការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ ឬការប្រព្រឹត្តជាបុគ្គល ឬដោយ*

---

[1] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធដោយសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ១២, ១៣ និងសេចក្តីសម្រេច។

[2] សំណើរបស់ [redacted] ស្នើសុំការអនុញ្ញាតឱ្យចូលមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D82 ("សំណើ")។

[3] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធដោយសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ ក.ស.ច.ស ("បណ្តឹងឧទ្ធរណ៍") ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2/1។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ពាក់ព័ន្ធនឹង [redacted] ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 កថាខណ្ឌ ៩៦ ដល់ ៩៩។ សូមមើល ផងដែរ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D[illegible]។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

*ចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ចំពោះបទឧក្រិដ្ឋខាងក្រោមដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦* (“ការជូនដំណឹងជាលាយលក្ខណ៍អក្សរ”)[5]។ នៅក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរ ស.ច.ស.អ.ប បានចាត់ទុក [redacted] ថាជា “*ជាជនសង្ស័យម្នាក់* នៅក្នុងកិច្ចស៊ើបសួរ*កំពុងបន្តដំណើរការ*” និងបានភ្ជាប់រូបគាត់ទៅនឹង*សិទ្ធិនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាម “វិធាន ៥៥(៦) វិធាន ៥៥(១) និង វិធាន ៥៨ នៃវិធានផ្ទៃក្នុង*”[6]។ ស.ច.ស.អ.ប បានជូនដំណឹង [redacted] ថា “*ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និង អង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ*”[7]។ ស.ច.ស.អ.ប បានជូនដំណឹង [redacted] ថា គាត់មានសិទ្ធិមួយចំនួន រួមទាំង *សិទ្ធិចូលពិនិត្យមើលសំណុំរឿង*[8] ផងដែរ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវបានក្រឡាបញ្ជីរបស់ ក.ស.ច.ស យកទៅជូនកូនប្រុសលោក [redacted] ឈ្មោះ [redacted] នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១២ នាវេលាម៉ោង ១០:៣០ ព្រឹក[9]។ នៅថ្ងៃដដែល គឺថ្ងៃទី១ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ១០:៥៧ ព្រឹក ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានបញ្ជាក់ថា ខ្លួន “ពុំអាចប្រគល់[ការជូនដំណឹង]” ដល់ [redacted] បានទេ ដោយសារមូលហេតុដូចតទៅ៖ “*យើងបានអានការជូនដំណឹងខាងលើឲ្យជនសង្ស័យស្តាប់។* ក្រោយពីស្តាប់ហើយ *ជនសង្ស័យបដិសេធមិនចុះហត្ថលេខាទទួលការជូនដំណឹងនេះទេ។* គាត់នឹងសហការជាមួយលោកចៅក្រម នៅពេលណាដែលបញ្ហារវាងសហចៅក្រមស៊ើបអង្កេតត្រូវបានដោះស្រាយរួចរាល់ ហើយគាត់មានពេលវេលាទំនេរ”[10]។

៣. នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ អ.គ.ក បានទទួលការណែនាំពី ស.ច.ស.អ.ប ឲ្យជួយ [redacted]

---

[5] *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* [វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង] ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D30 (“ការជូនដំណឹង”)។

[6] ការជូនដំណឹង កថាខណ្ឌសេចក្តីផ្តើម និងកថាខណ្ឌ ៤។

[7] ការជូនដំណឹង កថាខណ្ឌ ២។

[8] ការជូនដំណឹង កថាខណ្ឌ ៣។

[9] លិខិតបញ្ជាក់ពីការជូនដំណឹង (Acknowledgment of Service) ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D30.1។

[10] និវេទន៍នៃការមិនទទួលការជូនដំណឹង ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D30.1។

ក្នុងការជ្រើសរើសមេធាវីម្នាក់សម្រាប់ធ្វើជាតំណាងគាត់[11]។

៤. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ស.ច.ស.អ.ប បានចេញ "ដីកាសម្រេចលើយុត្តាធិការបុគ្គល និងគោលការណ៍ស៊ើបសួរពាក់ព័ន្ធនឹង [redacted]" ("ដីកាសម្រេចលើយុត្តាធិការបុគ្គល")[12]។ នៅក្នុងដីកាសម្រេចនេះ ស.ច.ស.អ.ប បានលើកឡើងថា "ពាក់ព័ន្ធនឹងភស្តុតាងដែលនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ *យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើជនសង្ស័យ* [redacted] *ដែលជា "មន្ត្រីខ្មែរក្រហមម្នាក់" ត្រូវបានបង្ហាញ*យ៉ាងពេញលេញ និងអាចជឿជាក់បាន[13]។ ស.ច.ស.អ.ប សម្រេចថា "ជនសង្ស័យ [redacted] *ត្រូវបាន*ចាត់ទុកជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូប ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរយៈកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩"។ ស.ច.ស.អ.ប បានធ្វើសេចក្តីសម្រេចនេះជាសាធារណៈ និងបានកត់សម្គាល់ថា "*ជនសង្ស័យ*ត្រូវបាន*ជូនដំណឹងពីបទចោទ*ប្រឆាំងនឹងរូបគាត់ តាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង"[14]។

**ការចូលរួម និងការទទួលស្គាល់សហមេធាវី៖**

៥. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ប្រធាន អ.គ.ក បានជូនដំណឹងទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ថា [redacted] បានជ្រើសរើសលោក អាង ឧត្តម និង លោក Michael KARNAVAS ជាសហមេធាវីរបស់គាត់ និងបានអញ្ជើញ ក.ស.ច.ស ឱ្យជូនដំណឹងពីការចាត់តាំងអ្នកទាំងពីរនេះ[15]។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យ ក.ស.ច.ស បដិសេធការតែងតាំងសហមេធាវីដោយចោទប្រកាន់ថាមានទំនាស់ផលប្រយោជន៍រវាងការធ្វើជាតំណាង [redacted] និង ការធ្វើជាតំណាង អៀង សារី ("សំណើរបស់ ក.ស.ព ស្តីពី

[11] *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ* [វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង] ទៅអង្គភាពគាំពារការការពារក្តី ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ D33។

[12] ដីកាសម្រេចលើយុត្តាធិការបុគ្គលនិងគោលការណ៍ស៊ើបសួរពាក់ព័ន្ធនឹង [redacted] ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D48។

[13] ដូចខាងលើ កថាខណ្ឌ ១០។

[14] ដូចខាងលើ សេចក្តីសម្រេច។

[15] លិខិតផ្ញើជូន ស.ច.ស ពាក់ព័ន្ធនឹងការចាត់តាំងមេធាវី ឱ្យធ្វើជាតំណាងលោក [redacted] ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D56។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C • C.E.T.C

ទំនាស់ផលប្រយោជន៍")[16]។ បញ្ហានៃការទទួលស្គាល់តាមផ្លូវតុលាការចំពោះការចាត់តាំងសហមេធាវីមិនទាន់ត្រូវបានសម្រេចស្ថាពរទេរហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ នៅពេលដែលអង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ស្ដីពីទំនាស់ផលប្រយោជន៍[17] ដែលត្រូវបានចេញជាការចាំបាច់ ដោយសារបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ប្រឆាំងនឹងសេចក្ដីសម្រេចមួយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបច្ចុប្បន្ន ("ស.ច.ស.អ")[18] ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ ដែលទទួលយកសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្ដីពីទំនាស់ផលប្រយោជន៍។ អង្គបុរេជំនុំជម្រះបានទទួលយកបណ្ដឹងឧទ្ធរណ៍របស់សហមេធាវី និងបានទទួលស្គាល់ពួកគេជាអ្នកតំណាងស្របច្បាប់របស់ [redacted][19]។

**សំណើ និងបណ្ដឹងឧទ្ធរណ៍៖**

៦. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣ សហមេធាវីការពារក្ដី [redacted] បានដាក់សំណើនេះជូន ក.ស.ច.ស។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ស.ច.ស.អ បានជូនដំណឹងដល់សហមេធាវីថា "ដោយសារតែវាអាចបង្កប់អត្ថន័យនៃទំនាស់ផលប្រយោជន៍ ដូចបានចោទ[ដោយសហព្រះរាជអាជ្ញាអន្តរជាតិ] *[សំណើសុំចូលពិនិត្យមើលសំណុំរឿង] នឹងត្រូវបានដោះស្រាយក្នុងពេលសមស្រប អាស្រ័យទៅលើលទ្ធផលនៃសេចក្ដីសម្រេចលើបញ្ហា [ទំនាស់ផលប្រយោជន៍]*"[20]។ នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវីបានដាក់ជូន ក.ស.ច.ស នូវ "ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធដោយសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំទាំង

---

[16] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D56/1។

[17] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ច្រានចោលការតែងតាំង អាង ឧត្តម និង Michael Karnavas ជាសហមេធាវី ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D56/19/36 ("សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីទំនាស់")។

[18] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបដិសេធការតែងតាំងសហមេធាវី ដែលត្រូវបានចាត់តាំងដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/18។

[19] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីទំនាស់។

[20] លិខិតរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងសារណារបស់សហមេធាវីដែលបានចាត់តាំងក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87។

១៤ របស់លោក [redacted] ដែលបានដាក់នៅ ក.ស.ច.ស”[21]។ សារណាមួយក្នុងចំណោមសារណាទាំងដប់បួនច្បាប់នោះគឺជាសំណើ[22]។ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវីបានដាក់សំណើជាភាសាអង់គ្លេសតែមួយគត់ នូវបណ្តឹងដែលបានជូនដំណឹងនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានជូនដំណឹងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣។ ពុំមានភាគីណាមួយបានដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះទេក្នុងកាលបរិច្ឆេទចុងក្រោយតាមច្បាប់។

៧. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញសាលដីការបស់ខ្លួនស្តីពីបណ្តឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងការបដិសេធតាមការសន្មត ចំពោះសារណា ១៤ ច្បាប់[23]។ នៅក្នុងសាលដីកានោះ ដោយកត់សម្គាល់ថា “ដោយមិនប៉ះពាល់ដល់ឋានៈរបស់ [redacted] នៅក្នុងកិច្ចដំណើរការនីតិវិធីស៊ើបសួរ ដោយសារថា៖

ក. ប្រសិនបើឋានៈរបស់ជនណាម្នាក់ក្នុងកិច្ចស៊ើបសួរ អនុញ្ញាតឲ្យធ្វើដូច្នេះមែន វិធានផ្ទៃក្នុងអនុញ្ញាតឲ្យចូលពិនិត្យមើលក្នុងសំណុំរឿង *តាមរយៈមេធាវីតែប៉ុណ្ណោះ*។ ហើយថា

ខ. បច្ចុប្បន្ន សហមេធាវី [redacted] កំពុងជំទាស់នឹងសេចក្តីសម្រេចលើទំនាស់ផលប្រយោជន៍”។

អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការសមស្របក្នុងការពន្យារសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ *ទាក់ទិននឹងសំណើសុំចូលពិនិត្យមើលសំណុំរឿង* “រហូតដល់ពេលអង្គបុរេជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើទំនាស់ផលប្រយោជន៍”[24]។

៨. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ដោយបានឃើញការទទួលស្គាល់មេធាវីការពារជនសង្ស័យនៅក្នុងដំណោះស្រាយនៃសេចក្តីសម្រេចរបស់ អ.ប.ជ ទៅលើបណ្តឹងឧទ្ធរណ៍អំពីទំនាស់ផលប្រយោជន៍ ស.ច.ស.អ យល់ឃើញថា “ពេលនេះជាពេលសមស្របក្នុងការពិចារណាទៅលើ

---

[21] ចុះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធដោយសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំទាំង ១៤ របស់លោក [redacted] ដែលបានដាក់ទៅ ក.ស.ច.ស ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D87/2។

[22] សូមមើល ជើងទំព័រ ១ ខាងលើ។

[23] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ ដែលបានដាក់នៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ DD87/2/2។

[24] ដូចខាងលើ។

សំណើរបស់មេធាវីការពារជនសង្ស័យ[ស្នើសុំការចូលពិនិត្យមើលសំណុំរឿង][25]។ ប៉ុន្តែ ស.ច.ស.អ យល់ឃើញទៀតថា "ការជូនដំណឹងទាក់ទងនឹងសិទ្ធិរបស់ជនសង្ស័យ និងសេចក្តីសម្រេចលើយុត្តាធិការបុគ្គល គឺសុទ្ធតែទាក់ទងទៅនឹងការកាត់សេចក្តីរបស់ខ្លួនទៅលើសំណើនេះ [ចូលពិនិត្យមើល...] ដោយហេតុថា សេចក្តីសម្រេចទាំងពីរនេះសុទ្ធតែបង្កើតបានជា សំអាងហេតុភ័ស្តុតាងពាក់ព័ន្ធនឹងជនសង្ស័យ ហើយការជូនដំណឹងអះអាងថានឹងផ្តល់ដល់ជនសង្ស័យនូវការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង០០៣"[26]។ ហេតុដូច្នេះ ស.ច.ស.អ ជូនដំណឹងដល់មេធាវីជនសង្ស័យ និងភាគី ក្នុងសំណុំរឿង០០៣ ថា ក្រោយពីអង្គបុរេជំនុំជម្រះទទួលស្គាល់មេធាវីជនសង្ស័យរួចមក ឥឡូវគាត់កំពុងតែពិចារណាឡើងវិញទៅលើការជូនដំណឹងអំពីសិទ្ធិជនសង្ស័យ និង សេចក្តីសម្រេចលើយុត្តាធិការបុគ្គល ក្នុងគោលបំណងសម្រេចសេចក្តីទៅលើសំណើ ហើយបានអញ្ជើញភាគី និងមេធាវីជនសង្ស័យឱ្យដាក់នូវការសង្កេតថែមទៀតដែលអាចមានទៅលើបញ្ហានេះ[27]។ ហេតុដូច្នេះ ស.ច.ស.អ ពន្យារការចេញសេចក្តីសម្រេចទៅលើសំណើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់គាត់សម្រេចថាតើត្រូវពិចារណាឡើងវិញលើសេចក្តីជូនដំណឹងដែលពាក់ព័ន្ធ និង សេចក្តីសម្រេចលើយុត្តាធិការបុគ្គលជាមុនសិន[28]។

៩. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ស.ច.ស.អ បានចេញសេចក្តីជូនដំណឹងទីពីរ ទាក់ទងនឹងលទ្ធភាពនៃការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចចំនួនពីរ ដែលបង្គាប់ឱ្យក្រឡាបញ្ជី ក.ស.ច.ស ផ្តល់ការអនុញ្ញាតដល់មេធាវីការពារក្តី [redacted] ចូលមើលសេចក្តីសន្និដ្ឋាននានារបស់ ក.ស.ព លើចំណុចនោះ ដើម្បីឱ្យមេធាវីការពារក្តីឆ្លើយតបវិញ[29]។

[25] ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងការស៊ើបអង្កេត (D28) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3។

[26] ដូចខាងលើ កថាខណ្ឌ១៥។

[27] ដូចខាងលើ កថាខណ្ឌ១៦។

[28] ដូចខាងលើ ដំណោះស្រាយ។

[29] សេចក្តីជូនដំណឹងលើកទីពីរទាក់ទងនឹងលទ្ធភាពនៃការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចចំនួនពីរ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D82/3/3/3។

01024517



## II. ការពិចារណា

១០. សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ដោយឈរលើមូលដ្ឋាននៃគោលការណ៍ "ការបដិសេធតាមការសន្មត" ហើយស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ និងបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតពិចារណា និងសម្រេចលើសំណើ[30]។

១១. ដោយពិចារណាលើមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលបានដាក់ និងសំណើដែលបានស្នើឡើង និងដោយឃើញដូចមានចែងនៅក្នុងប្រវត្តិនីតិវិធីខាងលើថា ស.ច.ស.អ កំពុងពិចារណាយ៉ាងសកម្មទៅលើសំណើនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ដែលថា ស.ច. ស.អ បានបដិសេធ*តាមការសន្មត*លើសំណើនោះ គឺជាទឡ្ហីករណ៍មិនពិត។ នៅក្នុងកាលៈទេសៈទាំងនេះ បណ្តឹឧទ្ធរណ៍ដែលបានដាក់ត្រូវចាត់ទុកជាអាសាបង់។

## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

បដិសេធបណ្តឹងឧទ្ធរណ៍នេះ ដោយគ្មានព្យសនកម្មដល់សិទ្ធិទាំងឡាយផ្សេងទៀតឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **នំយ ចុំល** **Chang-ho CHUNG** **ហួត វុទ្ធី**

[30] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៣។